# ល្បើកអង្គរវត្ត

## និពន្ធដោយ ម៉ាន់ តាត

## (១៥៤២ស័ក, ព.ស.២១៦៣, គ.ស.១៦២០)

(ចម្លងជាអក្សរ និងអក្ខរាវិរុទ្ធខ្មែរទំនើបដោយ ហម ឆាយលី តាមឯកសាររបស់អេម៉ូនីញេ អេត្យែនន៍ ដែលចម្លងដោយលោក សុន ឡៀប បោះពុម្ពនៅក្រុងព្រៃនគរ ឆ្នាំ១៨៧៨) ។

**កំណត់** : ការចម្លងជាថ្មី និងអក្ខរាវិរុទ្ធនេះ ខ្ញុំផ្ទៀងផ្ទាត់តាមវចនានុក្រមរបស់ពុទ្ធសាសនបណ្ឌិត្យ, ក្បាលទី១ បោះពុម្ព ឆ្នាំ១៩៦៧ និង ក្បាលទី២ បោះពុម្ព ឆ្នាំ១៩៦៨ ។

| | | | | |
|---|---|---|---|---|
| ១. | សាស័ព្ទសេដ្ឋោ | ឯកបញ្ចោ | សសោត្តមំ | ឆ្នាំវកនក្សត្រ |
| | វិវឌ្ឍនំ | សាធុការំ | តិលកាលំ | ។ |
| ២. | ខ្ញុំអង្គអំបូរ | ពូជពង្សត្រកូល | ជាតិវង្សា | នាមនៃអ្នកប៉ាង |
| | តាតសាងសាស្ត្រា | ល្បើកអង្គរជា | ច្បាប់ទៅមុខហោង ។ | |
| ៣. | មានចិត្រសទ្ធា | អាចចារសាស្ត្រា | ដោយដានគន្ធង | គាថាបាលី |
| | ពិតពីព្រេងហោង | មែនដូច្នេះហោង | ពុំឃ្លាតឡើយណា | ។ |
| ៤. | អង្គអញខ្ញុំសូម | សំណាងសំណូម | បានបរិបូណ៌ប្រា | កដដូចខ្ញុំគិត |
| | ក្នុងចិត្រប្រាថ្នា | កុំឱ្យមានឃ្លា | ឃ្លាតដល់តិចឡើយ ។ | |

### បទព្រហ្មគិត

| | | | |
|---|---|---|---|
| ៥. | តែងជាបទព្រហ្មគិត | លើកដោយគិតតាមទំនង | ដំណើរពីមុនហោង |
| | | អ្នកប្រាជ្ញលោកលើកមកស្រាប់ | ។ |
| ៦. | ខ្ញុំនៅសូមពណ្ណរាយ | ប្រកបកាយជាតិចំណាប់ | ចំណងចងជាស័ព្ទ |
| | | ជាត្រកាលពេកក្លាត់ណា | ។ |
| ៧. | អង្គអញសូមកំណើត | កបកាលកើតៗនៅនា | ស្ថានសួគ៌ត្រៃត្រឹង្សា |

ពិតពុំឃ្លាឃ្លាតឡើយហោង ។

៨. ខ្ញុំសូមកំណើតគាប់ ជាសម្រាប់ព្រះអង្គហោង ព្រះសីអារ្យកន្ទង
លែងទេព្ពានៅស្ងត់នាយ ។

៩. កាលព្រះចាកច្យុត ស្រៀបស្រាប់ស្រុតសោះសព្វសាយ ចាប់ព្រះបដិសន្ធិឆ្ងាយ
បរិបូណ៌បានត្រាសហើយហោង ។

១០. ខ្ញុំសូមកុំឱ្យឃ្លាត យោនយកជាតិថ្ងៃមួយផង ព្រះអង្គនោះឯងហោង
សូមបានដួចប៉ងប្រាថ្នា ។

១១. ខ្ញុំសូមបានរៀនធម៌ ចប់អស់អាចិត្រៃភេទផង សូមចិត្រល្អកន្ទង
ជាសំឡាញ់និងញាតិផៅ ។

១២. ខ្ញុំសូមមានសំឡឹង សូរស័ព្ទឈ្ងឹងក្រាំងក្រនី វម្ងាប់ចិត្រនិត្យនៅ
អស់អ្នកផងទប់ពុំបាន ។

១៣. ខ្ញុំសូមមានប្រាជ្ញា កាត់សទ្ធាពន់ប្រមាណ ខ្ញុំសូមបានឱ្យទាន
អស់ទាំងស្នូមយាចកផង ។

១៤. សំណួមនេះឯណា ខ្ញុំប្រាថ្នាស្រាប់ហើយហោង សូមបានដួចបំណង
នៃអញខ្ញុំសូមប្រាថ្នា ។

១៥. ត្រៃភពសារសុចរិត វវិវិគហប្ញទ័យា និនអង្គអរសទ្ធា
ត្រូញក្រាបក្រោមព្រះលាយលក្សណ៍។

១៦. ទោះទាំងផ្ទលីថ្កើង លុតលើកឡើងស្មោះដោមដាក់ សិរសាដាក់ជៀងជាក់
ថ្វាយវន្ទានិនលំអុត ។

១៧. ស្មោះស្មានពីចិត្រចង់ បង្គំត្រង់ព្រះសម្ពុទ្ធ ស្តែងស្តេចជាមកុដ
ត្រៃភពភាផងទាំងឡាយ ។

១៨. ព្រះអង្គគីភេត្រា មាលមាសមារតន៍រៀងរាយ រស្មីភ្ញីព្រោងព្រាយ
ចិញ្ចែងចាំងទាំងសាកល ។

១៩. ផ្ទលផ្ទុកសព្វសត្វផង នានាំឆ្លងដោមដាក់ដល់ និព្វានស្ថានមង្គល
ប្រាសនិរាសជាតិជរា ។



២០. នោះអញខ្ញុំសង្វាត ឧស្សាហ៍ឃ្លាតខ្វីចិន្តា ចាប់ចងជាកាព្យា
ស្លូត្រសរសើរព្រះបារមី ។

២១. ស្តេចអាចផ្ចាញមារា នោះពុះពារមារយាយី បាក់បបបង់ទិដ្ឋី
ទ្រើសលែងលុះដោយចេស្តា ។

២២. យើងខ្ញុំស្រណោះសល់ ដ្បិតពុំយល់ព្រះធម្មា យល់តែព្រះរូបា
ស្ថិតលើអាសនៈព្រះអង្គ ។

២៣. ទើបខ្ញុំត្រេកសទ្ធា និនសិរសាបង្គំផ្ចង់ ព្រះរូបប្រសើរទ្រង់
ប្រោសសត្វផងឯក្រោយណា ។

២៤. ស្រេចន័យនឹងថ្វាថ្លែង ចរចាថែងសរសើរមហា ប្រាសាទទាំងប្រាំប្រា
កដកបកពិចិត្រក្រៃ ។

២៥. ប្រាសាទនេះឯងណា ព្រះឥន្ទ្រាទិព្វទេពថ្ងៃ ប្រើព្រះពិស្ណុការនៃ
ចុះមកកថ្វាយក្សត្រា ។

២៦. កាល្ពោះអស្ចារ្យក្រៃ មានក្សត្រិយ៍ថ្ងៃសោយរាជា ស្តេចទ្រង់ព្រះនាមា
ហៅព្រះបាទវង្សអស្ចារ្យ ។

២៧. ស្តេចមានព្រះអំណាច សេពសោយរាជ្យនូវធម្មាំ គ្រប់គ្រងអស់រាស្ត្រណា
សឹងក្សេមដោយព្រះបារមី ។

២៨. ស្តេចមានវរជាយា ទ្រង់នាមាទៃវតី ឆោមឆាយស្រស់សោភី
ជាច្បងច្បាស់អស់ស្នំផង ។

២៩. អនេកនូវបរិពារ ស្រីស្រីង្គាឥតឯផ្លង ស្រីស្រស់ទន់ទងវង
រៀបរាយរៀងបំរើនិត្យ ។

៣០. ព្រះមហាក្សត្រិយ៍ត្រកូល ជាឥសូរអង្គឯកក្សត្រិយ៍ សឹងមកប្រណិប័តន៍
ថ្វាយបង្គំឥតឯឆ្លង ។

៣១. សឹងនាំភ្ញីប្រាក់មាស ច្រើនដេរដាសដោយពណ៌ហោង ដ៏ថ្វាយនូវសួយផង
ជាប្រក្រតីពុំដែលអាក់ ។

៣២. អនេកនូវទ្រព្យផង រតន៍កែវកងនូវមាសប្រាក់ ព្រំព្រៃវិស័យចាក់

ខៀនក្រឡាកាសាច័ន្ទ ។

៣៣. អនេកនូវដីរ រថពាជីរាជាយាន្ត ក្ទឹងក្ទស់នូវពិតាន
រាំងននៃនេបមាសមាលា ។

៣៤. អនេកនូវរេហ៍ពល ទាំងសាកលសែនយោធា ខុណាងមន្ត្រីត្រា
គ្រប់គង់គាល់ច្រើនក្រាស់ក្រៃ ។

៣៥. ស្តេចមានព្រះរាជបុត្រ ប្រុសពិសុទ្ធពិសេសក្រៃ ប្រសើរព្រះនាមនៃ
ហៅព្រះកេតុមាលាហោង ។

៣៦. វីព្រះរាជកុមារ បុណ្យសម្ភារក្រៃកន្ទង ឮខ្ចរសព្ទសាយហោង
អស្ចារ្យកើតកាល្ពោះណា ។

៣៧. កក្រើកដាលដួចដល់ សួគ៌សាកលត្រៃត្រឹង្សា សម្តេចព្រះឥន្ទ្រា
បើកទិព្វចក្ខុមើលមកហោង ។

៣៨. យល់ព្រះរាជកុមារ មានសម្ភារក្រៃកន្ទង ជៀងជាក់ជាច្បាស់ច្បង
លើសលែងលុងលើក្សត្រា ។

៣៩. ដឹងដើមបុត្របូរាណ ចុះចាកស្ថានត្រៃត្រឹង្សា យកបដិសន្ធិជា
បុត្រព្រះបាទវង្សអស្ចារ្យ ។

៤០. សម្តេចព្រះឥន្ទ្រធ្យាន ដឹងដោយញាណឯងអស់អាថ៌ ជៀងជាក់សោះសព្ទសារ-
ពើពិតពុំសន្ទិះឡើយ ។

៤១. ទើបស្តេចចុះចាក់ស្ថាន សួគ៌ភីមានពុំលង់ឡើយ យករាជកុមារហើយ
នាំទៀងទៅត្រៃត្រឹង្សា ។

៤២. ព្រះឥន្ទ្រស្តេចសន្ទត់ ជាក់ជាបុត្រព្រះអង្គណា ស្រឡាញ់ថ្នមរក្សា
ហាក់កើតពីឧទរា ។

៤៣. កាល្ពោះទេពសួគ៌ស្ថាន នៅពុំក្សាន្តសប្បាយណា សឹងឈឺព្រះសិរសា
ដ្បិតធុំក្លិនមនុស្សវិស័យ ។

៤៤. ទេព្តាផងរំជួល សឹងឱ្យកខ្យល់ជាទុក្ខក្រៃ ពុំអាចទប់ទីទៃ
ឡើងទៅទូលព្រះឥន្ទ្រា ។



៤៥. បរពិត្រទេពឥស្វរ ជាកំពូលលើសិរសា ដោយច្បាប់ស្ថានសួគ៌ា
ពុំដែលមានដូច្នេះនៃ ។

៤៦. នាស្តេចយាងយោនយក បុត្រមោះមកសួគ៌ាលៃ យើងខ្ញុំផងទីទៃ
ធុំក្លិនមនុស្សនៅពុំក្សាន្ត ។

៤៧. នោះទើបព្រះឥន្ទ្រា- ធិរាជាបន្ទូលថ្កាន ថាហេតុបុត្របូរាណ
អញឯងហោងទើបនាំមក ។

៤៨. បើដូច្នោះកុំតឹង ជាទុក្ខនឹងបុត្រពន្ទក អញបានជាយកមក
ហើយអញនឹងជូនចុះទៅ ។

៤៩. កាល្ពោះឯក្សត្រា កេតុមាលារាជចោមចៅ អាល័យដ្បិតធ្លាប់នៅ
ប្រាសាទទាំងប្រាំសមស្រេច ។

៥០. នាមហៅពេជ្រយ័ន្តរថ ចិញ្ចែងក្លាត់សមក្សរក្សាច់ ព្រោងប្រុះឆ្នុះរំលេច
ច្រាលច្រវាត់យល់សព្វសាយ ។

៥១. ដាំដាសពាសនីទៅ រតន៍ឆ្នុះឆ្លៅមាសព្រោងព្រាយ មរកតកែមពិទាយ
ពេជ្រពពាលរតន៍រៀងរាល់ ។

៥២. ពិទូរ្យសូរ្យកាន្តកែម និលលក្ខណ៍លែមកែមកបកាល បួទមប្រាក់ៗពណ៌
មុក្តាដាច់ផ្ទេករតន៍រាយ ។

៥៣. ទទឹមទឹកស្រស់ស្រិល ឥន្ទ្រនិលតារាកាយ ពិទ្រុមទ្រុឌសព្វសាយ
កញ្ចក់ថៃមមាសមណី ។

៥៤. ប្រាក់ប្រុះឆ្នុះព្រោងព្រាយ សែងសូរ្យសាយនូវបក្សី រួតរាក់ឆ្លាក់នូវភ្ញី
ល្អប្រសើរឥតផ្ទឹមបាន ។

៥៥. រុងរឿងថ្កើងល្អស្រស់ ដោមខ្ពង់ខ្ពស់ប្រាសាទស្ថាន មួយពាន់យោជន៍ប្រមាណ
ពីកំពូលទៀងទាល់ក្រោម ។

៥៦. កំពូលកំពស់ស្រួច ស្រោងត្រដួចត្រដឹងដោម ត្រដាច់កណ្តាលព្យោ-
មាអាកាសវេហាសហារ ។

៥៧. ឯក្នុងប្រាសាទសួគ៌ សឹងរំយោលពិតានដា ភ្ញីប្រុះឆ្នុះរន្ទាល

ទូវសុវណ្ណរតន៍រៀងរាយ ។

៥៨. រំយោលទងមាលា ទូវបុប្ផផងទាំងឡាយ រន្ទាលភ្ជីព្រោងព្រាយ
ផ្សព្វនីទៅទូវក្លិនក្បី ។

៥៩. ត្រសាកត្រសៀកល្វេង ស្នូរស័ព្ទភ្លេងភ្ញាត់តន្ត្រី របាំរបៀបស្រី-
ទេពអប្សររាំថ្វាយ ។

៦០. បវរវរសោភា អស់អង្គាទ្រង់ឆោមឆាយ ស្រឡះអង្គកែក្រាយ
ឆ្មៀលឆ្វាត់ឆ្វាយស្រួលឥតឆ្គង ។

៦១. បវរវរជួបចាប់ ទ្រង់គ្រឿងគ្រប់ប្រដាប់ផង សឹងស្រស់ៗទងវង
ទាំងបួនអង្គល្អប្រពៃ ។

៦២. សំរាប់ព្រះឥន្ទ្រា ចោមទេវាប្រសើរក្រៃ សេពសុខសម្បត្តិត្រៃ-
ត្រឹង្សពិភពស្ងួតាំលៃ ។

៦៣. មើលមានកាលប្ញព្រឹក្ស សោតសន្ទឹកខ្ពស់ត្រឡៃ ខ្យល់បក់ល្ងន់ល្វាសក្រៃ
មែកស្ទោមស្លឹកប្រសព្វគ្នា ។

៦៤. គន់ទៅនន្ទឧទ្យាន សប្បាយក្សាន្តក្នុងចិន្តា សម្រាប់អង្គឥន្ទ្រា
ជាឆ្មើមឆ្មួតអស់ទេពផង ។

៦៥. វីអស់ទេពកញ្ញា តែងឧស្សាហ៍នាំគ្នាផង ច្រៀងច្រូចស្នូរស័ព្ទកង
លេងសព្វដោយត្បូទីទៃ ។

៦៦. មានទាំងដើមបរិឆត្រ ខ្ពស់ដោមខ្វាត់មែកត្រឡៃ កំពស់ស្រោងល្ងួតលៃ
ហាសិបយោជន៍បរិមណ្ឌល ។

៦៧. ទ្រង់ផ្កាវង់ដូចឆត្រ ក្លិនក្បែបខ្វាត់រយយោជន៍យល់ ទេព្តាផងរវល់
សេពសោយសុខក្លិនបុប្ផ ។

៦៨. ពុំដែលនឹងល្ហិតល្ហៃ ជាសុខក្រៃក្នុងអាត្មា មានអស់ផ្កាបរិវារ
ដុះជាជួររៀបរៀងរាយ ។

៦៩. ខ្ទឹងក្ទម្ពកែកាកេស ក្លិនពិសេសធំភាសភាយ រំចេកកាកែសលាយ
ផ្គុលភ្ញួជាន់ទូវមហាហង្ស ។



៧០. ពុតធ្វើរកពាក់ព័ន្ធ ផ្កាអញ្ចន់ក្រអូបហង់ រំដួលទូវត្រយ៉ង់
មែកពាន់ពាក់ដើមចម្ប៉ា ។

៧១. ច័ន្ទមានលុង្គ្រែ ដុះបង្អែរទ្រង់បុប្ផ ស្រឡិតស្រឡីច្បារ
សអន្ទប្រាលខៀវអន្ទង ។

៧២. ក្តាំងជាទូវសុរភី ទ្រង់សឹងក្បីស្រស់ៗជ្រង លតាមាសទន់ទងវង
វារពាក់ព័ន្ធផ្កាទូនស្រី ។

៧៣. មង្រ្គដើមប្ញក្ជាប់ ស្រស់ស្រេចស្រាប់មានរស្មី រំដេញមាសរីកថ្មី
នៃបដាវរៀងលឿងក្រសែត ។

៧៤. អស់នាងទេពអប្សរ សឹងស្មោះសរអរអនេក ហែលហារបេះផ្កាចែក-
គ្នាក្រាលក្រងប្រដាប់អង្គ ។

៧៥. ខ្វះក្រងផ្ការំដួល រៀបជាជួរល្អបញ្ចង់ កើតឡើងដូចរូបហង្ស
តាងបក្ខាហើរហោះ ។

៧៦. នាងមួយជណ្តប់ស្បៃ ស្តើងប៉ប្រែដើរផ្ញេកផ្ញោះ បេះផ្កាដោយចន្ទោះ
ផ្កាម្ញិះរួតទូវម្ញិះលា ។

៧៧. ក្រងជារូបកិន្នរី ល្អពិសីមៀងមើលគ្នា នាងមួយមុខសើរ៉
ក្រងជារូបសោមបណ្ឌិត ។

៧៨. ខ្វះក្រងជាសារិកា- កែវពាំផ្កាហើយហើរជិត នៃបនិងសោមបណ្ឌិត
ទំផ្គងផ្ទៀងមៀងមើលគ្នា ។

៧៩. សឹងតែច្រៀងលេងសើច ខ្សៀវក្វាក់ខ្វើចគ្រប់គ្នីគ្នា និយាយហើយពណ៌នា
សរសើរបុណ្យអង្គកោសី ។

៨០. នាងខ្វះល្អឧត្តម យល់សំណមស្រស់ប្រិមប្រិយ អ្នកនាំអស់ទាំងស្រី
ទេពអប្សរចុះស្រះស្រី ។

៨១. ខ្វះហែលបេះផ្កាស្គន់ ល្អទន់ភ្ញន់សកំផ្ទង់ លាយនិងផ្កាលិចង់
ផ្កានិលបុលទូវស្បង់កាច់ ។

៨២. ខ្វះសោតល្អស្រងៅ ធ្មេញស្រស់ខ្មៅហែលរដាច់ ដល់ហើយដៃកាន់កាច់

ផ្កាក្រមុំទទួវឈូកសែត ។

៨៣. បង្គួតបង្គួា ហែលរេរាត្រដោមដែត វាយទឹកលេងដោយហេតុ

រាល់ដើមផ្កាឈូកសផង ។

៨៤. បេះបានស្រេចកែក្រាយ លេងសប្បាយក្នុងស្រះស្រង់ នាងខ្លះហែលតម្រង់

បេះកាច់ឈូកក្នុងជលសា ។

**នេះបទភុជគលីលា**

៨៥. ព្រះកេតុស្ស្យវង្ស មៀងមើលរូបទ្រង់ អស់នាងកញ្ញា សើចលេងក្អាកក្អាយ

សប្បាយណាស់ណា មុខគួរស្នេហា ទូវនាងទាំងឡាយ ។

៨៦. ស្តេចគិតអាឡោះ អាល័យស្រណោះ ពុំចង់ឃ្លាតឆ្ងាយ គន់គិតជញ្ជីង

រំពឹងសព្វសាយ វែងគិតវែងស្តាយ ពុំចង់ឃ្លាតឃ្លា ។

៨៧. រីអស់ទេពផង នាំគ្នាត្រសង ក្រាបទូលឥន្ទ្រា ឱ្យស្តេចឆាប់នាំ

បុត្រស្ងួនពុំងា រួសរាន់ម្ចីម្នា មិនឲ្យយូរលង់ ។

៨៨. រីព្រះឥន្ទ្រា ចោមចៅទេវា អម្បូរពូជពង្ស អាសូរបុត្រស្ងួន

ខ្ញុំមខ្លួនវរវង្ស កប្បូរកបទ្រង់ លើសលែងនា។ ។

៨៩. ទើបស្តេចឆ្លាសឆ្លើយ ថាហៃទេពអើយ កុំគិតសង្ការ អញនឹងនាំបុត្រ

បរិសុទ្ធពុំងា ចរចាកឃ្លាតឃ្លា រួសរាន់ទៅហោង ។

៩០. ស្តេចលោមបុត្រា ថាស្ងួនស្នេហា សំឡាញ់ស្នេហ៍ស្នង អាពុកឱ្យជូន

កូនស្ងួនទៅហោង ឥឡូវជាម្តង ឥតឯរុញរា ។

៩១. ចៅកេតុស្សរិយោ ពិសេសសេដ្ឋោ ឆ្នូតឆ្នើមលោកា លើកករបង្គំ

ប្រណម្យបិតា ទើបក្រាបទូលថា បពិត្រម្ចាស់ថ្លៃ ។

៩២. ឆ្នើមអស់លោកា ច្បងលើទេវតា នៅនាស្ថានត្រៃ- ត្រឹង្សាពិភព

ស្ងួគ៏សក្តិសព្វថ្ងៃ ចិត្រខ្ញុំអាល័យ ពុំចង់ឃ្លាតឆ្ងាយ ។

៩៣. សម្តេចចក្កុន្ទ្រើយ ចោមចៅនរិន្ទ្រ ស្តាប់បុត្រដោមឆាយ ថាផ្សិតស្រណោះ

អាលោះស្ថានអាយ ស្រួលសុខសប្បាយ ឥតឯគណនា ។

៩៤. ទើបស្តេចឆ្លាសឆ្លើយ ថាហៃស្ងួនអើយ កុំថប់រុញរា និងពិភពស្ថាន



ភិមានស្ងួគាំ អាពុកជានា សាងឱ្យអ្នកថ្លៃ ។

៩៥. រីបុត្រស្នេហា ស្តែងស្តាប់បិតា សារសងស្ងួមៃ បើកនិស្ស័ប្រិម

ញញឹមប៉ប្រៃ និងព្រះចោមត្រៃ ជាតិជាបិតា ។

៩៦. បើស្តេចអាសូរ មេត្រីអនុកូល អញខ្ញុំករុណា សូមស្តេចយកស្ថាន

ភិមានទេវតា ស្តាងតាមសញ្ញា ចិត្រខ្ញុំបំណង ។

៩៧. ព្រះឥន្ទ្រឆ្លាសឆ្លើយ ថាហៃកូនអើយ កុំគិតឡើយហោង បិតានឹងយក

ស្ថានត្រៃត្រឹង្សា ស្តាងឱ្យអ្នកហោង កុំស្ងួនបារម្ភ ។

៩៨. សម្តេចទេវោ ប្រសើរវរោ ថ្វាថ្ងៃស្ងួស្តីសម ស្តេចលោមបុត្រស្ងួន

ខ្ញុំមខ្លួនឧត្តម មិនឱ្យបារម្ភ អស់កិច្ចការផង ។

៩៩. ទើបព្រះកេតុឆ្លើយ ថាអម្ចាស់អើយ ខ្ញុំអរពេកហោង សូមស្តេចប្រណី

ឃ្លាតខ្ញីជាម្តង ហៅអស់ទេពផង មកធ្វើម្ចីម្នា ។

១០០. រីព្រះទេវោ ជាតិជាអគ្គោ ស្តាប់បុត្រពុំងា បុត្រចិត្រចង់ឆាប់

ប្រញាប់មហិមា ស្តេចរៀបដោយនា ហឫទ័យចំណង់ ។

១០១. ឱ្យអស់ទេវតា តាក់តែងសព្វសា- រពើការផង ទាំងព្រះចតុល្នោក-

កបាលហោះផ្សង ភ្ញុំពលស្រេចហោង ទេវបុត្រទេវតា ។

១០២. គិតគន់ឱ្យយក ពេជ្រយ័ន្តនោះមក សាងឱ្យបុត្រា យង់យល់ធំខ្ពស់

ពាន់យោជន៍សោះសា អស់ទាំងទេព្តា ស្ងប់ស្ងែងទីទៃ ។

១០៣. សម្តេចសក្កោ ប្រសើរសេដ្ឋោ រំពឹងរំពៃ និងព្រះពិស្ណុកា

ប្រាជ្ញាឆ្លៀងវៃ យល់ល្មមតែន័យ ស្ថានតែងជំនុំ ។

១០៤. ឈ្មោះហៅរោងធម៏ សភាឧត្តម ទេវតាជួបជុំ នោះល្មមឱ្យសាង

គ្រាន់និងបន្ទុំ បារមីមូលជុំ ឯមនុស្សលោកា ។

១០៥. គិតព្រមស្រាប់ស្រេច ទៀងទើបសម្តេច សហស្សចក្ខា អស់បរិពារផង

សែនកោដិសំខ្យា ទេវបុត្រទេវតា ចុះមកជាម្តង ។

១០៦. សាងទាំងព្រះគោ ប្រសើរវរោ អង្គមួយមកផង ជាអ្នករក្សា

ទីស្ថានសព្វផង កុំឱ្យហៅហ្មង ដល់រាជបុត្រា ។